ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់ទៅនឹង
ការប្រែប្រួលអាកាសធាតុ (ASPIRE)

# ការគ្រប់គ្រង និងប្រើប្រាស់មណ្ឌលប្រមូលផ្ដុំកសិផល

## សម្រាប់បណ្ដុំអាជីវកម្ម ដែលគាំទ្រដោយកម្មវិធី ASPIRE

## (Agricultural Collecting Centre)



រៀបចំដោយ៖ លេខាធិការដ្ឋានកម្មវិធី ASPIRE

ឆ្នាំ ២០២១

# មាតិកា


១. សេចក្តីផ្តើម ........ ១

២. គោលបំណង ........ ២

៣. ការកំណត់ទីតាំង ........ ៣

៤.គោលការណ៍គ្រប់គ្រង ប្រើប្រាស់ និងថែទាំ ........ ៣

៥. គោលការណ៍នៃការអាជីវកម្ម ........ ៨

៦. តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ ........ ១០

៧.ទម្រង់ឯកសារនានា ........ ១៣

## ១. សេចក្តីផ្តើម

កម្មវិធីផ្សព្វផ្សាយបច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) គឺជាកម្មវិធីមានរយៈពេល ៧ ឆ្នាំរបស់រាជរដ្ឋាភិបាលកម្ពុជា។ គោលដៅអភិវឌ្ឍន៍ជារួមនៃកម្មវិធីគឺកាត់បន្ថយភាពក្រីក្រនិងបង្កើនភាពធន់របស់គ្រួសារក្រីក្រនិងងាយរងគ្រោះចំនួន ១៩៥.០០០ គ្រួសារនៅកម្ពុជាដោយបង្កើនតម្លៃផលិតកម្មកសិកម្មជាលក្ខណៈគ្រួសារជាមធ្យម ២០% និងតម្លៃទ្រព្យសម្បត្តិគ្រួសារ ២៥% ។ គោលបំណងនៃការអភិវឌ្ឍគឺដើម្បីបង្កើតនូវគំរូកសិកម្មនៅកម្ពុជាដែលត្រូវបានបង្ហាញថាមានប្រសិទ្ធិភាពក្នុងការជួយដល់កសិករដែលមានទំហំផលិតកម្មតូច មានផលិតកម្មចម្រុះ ដើម្បីរួមចំណែកដល់កំណើនសេដ្ឋកិច្ចដែលមានលក្ខណៈទូលំទូលាយតាមរយៈអាជីវកម្មកសិកម្ម ទទួលបានប្រាក់ចំណេញនិងភាពធន់ ហើយត្រូវបានយកមករៀបចំជាគោលនយោបាយនៅឆ្នាំ២០២១។

កម្មវិធី ASPIRE កំពុងផ្លាស់ប្តូរពីសេវាផ្សព្វផ្សាយផ្តោតលើផលិតកម្មដែលផ្តល់ដោយទីភ្នាក់ងាររបស់រដ្ឋ ទៅ វិធីសាស្ត្រជំរុញការផលិតផ្តោតលើទីផ្សារបន្ថែមទៀត តាមរយៈការចងក្រងនិងអភិវឌ្ឍបណ្តុំអាជីវកម្មដែលមានក្រុមផលិត ពាណិជ្ជករ/អ្នកប្រមូលទិញ និងអ្នកផ្គត់ផ្គង់ធាតុចូលកសិកម្ម រួមគ្នាធ្វើអាជីវកម្ម។ សមាសភាពសមាជិកនៃបណ្តុំអាជីវកម្មនេះ អាចជួយឱ្យតួអង្គខ្សែច្រវ៉ាក់តម្លៃបង្កើតទំនាក់ទំនង និងបណ្តាញអាជីវកម្មនៅក្នុងមុខទំនិញកសិផលជាក់លាក់ដើម្បីកែលម្អអាជីវកម្មកសិកម្ម របស់ពួកគេ។ បច្ចុប្បន្នមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្នុងក្របខ័ណ្ឌថវិកាកម្មវិធី ASPIRE បានជួយសម្រួលដល់ការបង្កើតបណ្តុំអាជីវកម្មចំនួន ២ ៥៣០ ដែលមានសមាជិកជាង ៨៧ ១២៧ គ្រួសារ នៅទូទាំងខេត្តគោលដៅដែលមានកសិផលជាច្រើន រួមមាន បន្លែ អង្ករ ត្រីសាច់ កង្កែប សាច់មាន់ ដំឡូងមី ផ្លែឈើ បសុសត្វ ផលិតផលជលផល និងផលពីអនុផលព្រៃឈើជាច្រើនទៀត។ តាមរយៈវេទិកាតម្រង់ទិសអាជីវកម្ម សមាជិកបណ្តុំអាជីវកម្មទទួលបានការគ្រប់គ្រងលើទំនាក់ទំនងសេដ្ឋកិច្ចរវាងតួអង្គខ្សែច្រវ៉ាក់តម្លៃ។ លើសពីនេះទៀត កម្មវិធី ASPIRE បច្ចុប្បន្នកំពុងធ្វើការជាមួយសហគមន៍កសិកម្មជាង ២៥០ និងកសិករឆ្នើមចំនួន ៥០០ នាក់។ សហគមន៍កសិកម្ម និងកសិករឆ្នើមទាំងនេះគឺជាអ្នកដើរតួយ៉ាងសំខាន់ក្នុងការផ្សារភ្ជាប់ទីផ្សារជាមួយកសិករដែលមានទំហំផលិតកម្មតូច។

ការប្រមូលផ្តុំបណ្តុំអាជីវកម្ម និងសហគមន៍កសិកម្មបានបើកឱកាសឲ្យកសិករដែលមានទំហំផលិតកម្មតូចជាសមាជិកទទួលបានទីផ្សារថ្មីៗ។ ពួកគេអាចទាក់ទាញអ្នកប្រមូលទិញ និងអ្នកផ្គត់ផ្គង់ រួមទាំងស្ថាប័នមីក្រូហិរញ្ញវត្ថុ ដែលអ្នកទាំងនេះនឹងក្លាយជាកម្លាំងចលករជំរុញផលិតកម្ម និងអាជីវកម្មឲ្យបានកាន់តែប្រសើរ ទទួលបានផលចំណេញព្រមគ្នា ទាំងគ្រប់ភាគី

ដែលជាតួអង្គនៃបណ្តុំអាជីវកម្មប្រមូលផ្តុំមួយ។ ទោះយ៉ាងណាក៏ដោយមណ្ឌលប្រមូលផ្តុំកសិផល គឺជាស្នូលនៃបណ្តុំអាជីវកម្ម ឬសហគមន៍កសិកម្មសម្រាប់ជាកន្លែងបង្ហាញ និងដាក់លក់កសិផល របស់ពួកគេ ហើយវាមានការចាំបាច់បំផុតសម្រាប់ធានាគុណភាពទីផ្សារកសិផល ហើយក៏ជា កន្លែងបង្ហាញពីភាពរស់រវើកប្រកបដោយនិរន្តរភាពនៃអាជីវកម្មរបស់បណ្តុំអាជីវកម្មផងដែរ។ បច្ចុប្បន្នកម្មវិធី ASPIRE បាននិងកំពុងធ្វើការវិនិយោគរួមគ្នាជាមួយបណ្តុំអាជីវកម្ម សហគមន៍កសិកម្ម កសិករឆ្នើម និងអ្នកប្រមូលទិញក្នុងស្រុកដែលមានឆន្ទៈ ដើម្បីសាងសង់អគារមណ្ឌលប្រមូលផ្តុំកសិផលនេះ ដើម្បីបម្រើមិនត្រឹមតែជា"កន្លែងទិញ-លក់កសិផល" ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាកន្លែងជួបផ្លាស់ប្តូរបទពិសោធន៍ក្នុងការលើកកម្ពស់កសិផលរបស់កសិករក្នុងស្រុកផងដែរ។

ទោះបីអគារមណ្ឌលប្រមូលផ្តុំកសិផលនេះ នឹងត្រូវបានសាងសង់នៅក្នុងបរិវេណដីរបស់សមាជិកបណ្តុំអាជីវកម្មណាម្នាក់ក៏ដោយ អត្ថប្រយោជន៍នឹងមាននៅទូទាំងសហគមន៍។ សម្រាប់បណ្តុំអាជីវកម្មសមាជិកនឹងសម្រេចចិត្តលើការរៀបចំសម្រាប់ការប្រើប្រាស់ ការគ្រប់គ្រង និងប្រតិបត្តិការមណ្ឌលនេះ ព្រមទាំងចូលរួមជាទុនសហវិនិយោគក្នុងការសាងសង់ និងបំពាក់សម្ភារនានាក្នុងមណ្ឌលប្រមូលផ្តុំកសិផលនេះផងដែរ។ ភាគរយនៃប្រាក់ចំណេញពីការលក់ផលិតផលនឹងត្រូវបានទុកមួយឡែក ហើយដាក់ចូលទៅក្នុងមូលនិធិវិលជុំរបស់បណ្តុំអាជីវកម្មសម្រាប់កែលម្អ ថែរក្សា ប្រតិបត្តិការ និងវិនិយោគបន្ថែមទៀតរបស់បណ្តុំអាជីវកម្ម ឬសហគមន៍ ។ ប្រសិនបើមណ្ឌលប្រមូលផ្តុំនេះ ត្រូវបានផ្តល់ដល់សហគមន៍កសិកម្ម ការប្រើប្រាស់និងភាគលាភនឹងត្រូវបានកំណត់ដោយផ្អែកលើបទបញ្ជាផ្ទៃក្នុងរបស់សហគមន៍កសិកម្ម ។

## ២. គោលបំណង

ASPIRE គាំទ្រ និងបង្កើតឲ្យមានមណ្ឌលប្រមូលផ្តុំកសិផលនេះឡើង ក្នុងគោលបំណង ៖

- ធ្វើជាកន្លែងប្រមូលទិញ-លក់កសិផលរបស់បណ្តុំអាជីវកម្មតាមកិច្ចសន្យា
- ធ្វើជាកន្លែងសម្រាប់ទិញ-លក់ធាតុចូលកសិកម្ម ដល់សមាជិកបណ្តុំអាជីវកម្មទាំងអស់ និងកសិករផ្សេងៗទៀត
- បង្កភាពងាយស្រួលរបស់អ្នកប្រមូលទិញក្នុងស្រុក ក្នុងការទិញកសិផលដែលមានគុណភាព និងសុវត្ថិភាពនៅមូលដ្ឋាន
- ធ្វើជាទីតាំងសម្រាប់ប្រជុំការងារអាជីវកម្មកសិកម្ម ចែករំលែកបទពិសោធន៍និងចំណេះដឹងជំនាញកសិកម្ម និងព័ត៌មានទីផ្សារកសិផល
- លើកទឹកចិត្តវិស័យឯកជនឲ្យចូលរួមវិនិយោគជាមួយបណ្តុំអាជីវកម្ម និងសហគមន៍មូលដ្ឋាន។

- បំពេញបន្ថែមនូវហេដ្ឋារចនាសម្ព័ន្ធទីផ្សារកសិផលនៅមូលដ្ឋាន សម្រាប់កសិករដែលមានទំហំផលិតកម្មតូច។
- ធ្វើជាកន្លែងសម្រាប់រួមគ្នាពិនិត្យ និងកំណត់កម្រិតគុណភាពកសិផល (គុណភាពលេខ១ ឬលេខ២..) របស់សមាជិកម្នាក់ៗ ដើម្បីធានាទំនុកចិត្ត និងនិរន្តរភាពទីផ្សារ។

## ៣. ការកំណត់ទីតាំង

ទីតាំងមណ្ឌលប្រមូលផ្ដុំកសិផល ត្រូវបានជ្រើសរើសតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- នៅលើដីរួមរបស់សហគមន៍កសិកម្ម ឬ កសិករគំរូ (Lead farmer) /កសិករប្រមូលទិញ/ កសិករលក់ធាតុចូល ដែលជាសមាជិកបណ្ដុំអាជីវកម្ម ឬ សហគមន៍កសិកម្ម ហើយទីតាំងនោះគឺអាចប្រើប្រាស់ជាប្រយោជន៍រួមគ្នាបាន
- នៅតំបន់ដែលមានបណ្ដុំអាជីវកម្ម ហើយសមាជិកបណ្ដុំអាជីវកម្មងាយស្រួលយកផលិតផលមកដាក់លក់រួមគ្នា
- ជាកន្លែងដែលសាធារណៈជនអាចមើលឃើញ មានផ្លូវសម្រាប់រថយន្ត ម៉ូតូ រ៉ឺម៉ក ឬ មធ្យោបាយដឹកជញ្ជូននានា អាចចូលដឹកកសិផលចេញ-ចូលទៅកាន់ទីផ្សារបានស្រួល មានប្រពន្ធ័អគ្គិសនី (បើជាកន្លែងដែលមាន សេវាអ៊ីនធ័រណេត និងប្រព័ន្ធទឹកប្រើប្រាស់ កាន់តែប្រសើរ)
- មានផ្ទៃដីធំទូលាយដែលអាចសង់ពង្រីកបន្ថែមទៀតបាននូវកន្លែងសម្រាប់លាងសម្អាត វេចខ្ចប់ និងទុកដាក់កសិផលប្រកបដោយសុវត្ថិភាពនៅពេលអនាគតបាន
- បើជាដីឯកជន ម្ចាស់ដីត្រូវតែយល់ព្រម និងធ្វើកិច្ចសន្យាផ្ទៃក្នុងដោយមានការទទួលដឹងឮពីអាជ្ញាធរមូលដ្ឋាន ក្នុងការប្រើប្រាស់សំណង់នេះថាជាកម្មសិទ្ធរួមរបស់បណ្ដុំអាជីវកម្ម
- បណ្ដុំអាជីវកម្ម ត្រូវមានទុនសហវិនិយោគចូលរួមក្នុងការសាងសង់អគារមណ្ឌលប្រមូលផ្ដុំកសិផលនេះ។ ទុនសហវិនិយោគ អាចចំណាយលើ ៖ (១).ទូ/ធ្នើ/សម្ភារ សម្រាប់ដាក់កសិផល (២).សម្ភារសម្រាប់លាងសំអាតកសិផល (៣).ឧបករណ៍បម្រើដល់ការងារវេចខ្ចប់ (៤).ការតសំយ៉ាបបន្ថែម និង (៥).សម្ភារ/ឧបករណ៍ផ្សេងៗទៀតដែលបម្រើដល់ការងារអាជីវកម្ម កសិផលរបស់បណ្ដុំអាជីវកម្មតាមរយៈមណ្ឌលប្រមូលផ្ដុំនេះ។

## ៤. គោលការណ៍គ្រប់គ្រង ប្រើប្រាស់ និងថែទាំ

### ក). គោលការណ៍គ្រប់គ្រង

មណ្ឌលប្រមូលផ្ដុំកសិផលនេះ ត្រូវបានគ្រប់គ្រងដោយគណៈកម្មការមួយ ដែលកើតឡើងពីការបោះឆ្នោតដោយសមាជិកបណ្ដុំអាជីវកម្មទាំងអស់ ឬយ៉ាងហោចណាស់៨០%នៃចំនួន

សមាជិកសរុបទាំងអស់ដែរ។ ការបោះឆ្នោតត្រូវដំណើរការតែមួយពេលនិងសម្របសម្រួលដោយភ្នាក់ងារផ្សព្វផ្សាយឃុំ (CEW) និងប្រធានបណ្តុំអាជីវកម្ម និងមានចូលរួមជាសាក្សីពីអាជ្ញាធរមូលដ្ឋានផងដែរ។ គណៈកម្មការនេះ មានអាណត្តិការងាររយៈពេល០៣ឆ្នាំ ដែលមានសមាសភាពចំនួន ០៥រូប រួមមាន ប្រធាន ០១រូប អនុប្រធាន ០១រូប ហិរញ្ញិក/លេខា ០១រូប អ្នកត្រួតពិនិត្យគុណភាពកសិផល ០១រូប និងអ្នកសម្របសម្រួលទីផ្សារ ០១រូប។ រចនាសម្ព័ន្ធគ្រប់គ្រង និងតួនាទីភារកិច្ចរបស់គណៈកម្មការ មានដូចខាងក្រោម៖




**តារាងទី១៖ តួនាទី ភារកិច្ច និងការទទួលខុសត្រូវរបស់គណៈកម្មការគ្រប់គ្រង**

| តួនាទី | ភារកិច្ច | ការទទួលខុសត្រូវ |
|---|---|---|
| **ប្រធានមណ្ឌលប្រមូលផ្តុំកសិផល** | • រៀបចំផែនការផលិតកម្ម និងកាលវិភាគដាំដុះ/ចិញ្ចឹម ស្របតាមកិច្ចសន្យា ឬ តាមតម្រូវការទីផ្សារ ជាទៀងទាត់<br>• ចុះតាមដានកាលវិភាគដាំដុះ និងចិញ្ចឹមដល់សមាជិកបណ្តុំអាជីវកម្មនីមួយៗ<br>• ដឹកនាំ និងសម្របសម្រួលការប្រមូលកសិផល ពីសមាជិកបណ្តុំអាជីវកម្ម<br>• ចុះហត្ថលេខាលើទម្រង់ឯកសារដឹកជញ្ជូនកសិផល និងឯកសារហិរញ្ញវត្ថុផ្សេងៗ<br>• ប្តូកសរុបទិន្នន័យពីការលក់កសិផល របស់មណ្ឌលទាំងមូល<br>• រៀបចំនិងសម្របសម្រួលអង្គប្រជុំ ដើម្បីរៀបចំផែនការផលិតកម្មបន្តផែនការផ្គត់ផ្គង់ធាតុចូល ការចែករំលែកពីបទពិសោធន៍បច្ចេកទេស និងព័ត៌មានទីផ្សារ...។ល។ | • ត្រូវប្រាកដថា កសិផលដែលយកមកដាក់ក្នុងមណ្ឌល ត្រូវបានលក់ចេញទាំងអស់<br>• ត្រូវប្រាកដថាមិនមានជម្លោះធ្ងន់ធ្ងរកើតឡើង<br>• ត្រូវប្រាកដថាផែនការត្រូវបានអនុវត្តដោយរលូន<br>• ត្រូវប្រាកដថាកសិផលដែលបានប្រមូលមានគុណភាពស្របតាមកិច្ចសន្យា<br>• ធ្វើឲ្យក្រុមការងារសកម្មនិងមានភាពជឿជាក់លើគ្នាទៅវិញទៅមក<br>• ដឹកនាំឲ្យមានសាមគ្គីភាព |

| | | |
|---|---|---|
| | • ចាត់ចែងឲ្យមានអ្នកប្រចាំការជាប់លាប់នៅមណ្ឌលប្រមូលផ្តុំកសិផល។ | • ធ្វើឲ្យមានភាពច្បាស់លាស់ និងតម្លាភាពផ្នែកហិរញ្ញវត្ថុ |
| **អនុប្រធានមណ្ឌលប្រមូលផ្តុំកសិផល** | ជួយប្រធានលើការងារដូចខាងក្រោម៖<br>• ទំនាក់ទំនងទីផ្សារ និងក្តាប់ឲ្យបានអំពី តម្រូវការទីផ្សារ<br>• រៀបចំកិច្ចប្រជុំផ្លាស់ប្តូរបទពិសោធន៍គ្នាទៅវិញទៅមក អំពីបច្ចេកទេសកសិកម្ម ឬដោះស្រាយបញ្ហាបច្ចេកទេសនានា ដែលកើតមានចំពោះបណ្តុំអាជីវកម្ម<br>• កំណត់កសិករដែលជោគជ័យ លើការងារដាំដុះ ឬ/និងចិញ្ចឹមសត្វ ដើម្បីចែករំលែកបទពិសោធន៍ទៅដល់កសិករដទៃទៀតក្នុងបណ្តុំអាជីវកម្ម<br>• រៀបចំឲ្យមានកសិដ្ឋានគំរូសម្រាប់រៀនសូត្រ និងពិសោធន៍ផ្សេងៗ<br>• ទំនាក់ទំនងជាមួយស្ថាប័នដែលមានជំនាញគ្រប់គ្រាន់ ដើម្បីដោះស្រាយបញ្ហាជូនសមាជិកបណ្តុំអាជិវកម្ម<br>• អនុវត្តកិច្ចការផ្សេងៗទៀត តាមការណែនាំរបស់ប្រធានមណ្ឌល។ | • ត្រូវប្រាកដថា ព័ត៌មានស្តីពីតម្លៃ គុណភាព និងបរិមាណកសិផល ដែលទីផ្សារត្រូវការត្រូវបានផ្តល់ជូនសមាជិកបណ្តុំទាន់ពេលវេលា<br>• ត្រូវប្រាកដថា រាល់បញ្ហាបច្ចេកទេសទាំងអស់របស់សមាជិកបណ្តុំអាជីវកម្ម ត្រូវបានជួយដោះស្រាយទាន់ពេលវេលា<br>• ជួយរៀបចំផែនការដាំដុះចិញ្ចឹម ដើម្បីធានាបាននូវភាពទៀតទាត់នៃការផ្គត់ផ្គង់ទីផ្សារតាមកិច្ចសន្យា<br>• ពិនិត្យឡើងវិញការបែងចែកចំណាត់ថ្នាក់កសិផលតាមគុណភាព និងបរិមាណដើម្បីផ្គត់ផ្គង់តាមការតម្រូវរបស់អ្នកទិញ។ |
| **អ្នកពិនិត្យគុណភាព** | • ចុះពិនិត្យមើលកសិផល នៅតាមសមាជិកបណ្តុំអាជីវកម្មនីមួយៗ ដើម្បីធានាថា កសិផលទាំងនោះគឺមានសុវត្ថិភាពសម្រាប់សុខភាព<br>• ផ្តល់ការណែនាំ/បង្រៀនដល់សមាជិកបណ្តុំ អំពីការបែងចែកគុណភាពកសិផលរៀងៗខ្លួន និងការវេចខ្ចប់ដែលជាតម្រូវការទីផ្សារ និងអនាម័យខ្ពស់<br>• ចុះត្រួតពិនិត្យពីការប្រមូលផល ការលាងសម្អាត ការវេចខ្ចប់ និងការដឹកជញ្ជូនកសិផល របស់សមាជិកបណ្តុំអាជីវកម្មនីមួយៗ | • ត្រូវប្រាកដថា កសិផលដែលប្រមូលមកមណ្ឌលប្រមូលផ្តុំគឺមានសុវត្ថិភាព និងគុណភាពស្របតាមការតម្រូវរបស់អ្នកប្រមូលទិញចង់បាន<br>• មានទំនាក់ទំនងល្អជាមួយសមាជិកបណ្តុំអាជីវកម្មដែលជាក្រុមផលិត។ |

| | | |
|---|---|---|
| **អ្នកសម្របសម្រួលទីផ្សារ** | • សម្របសម្រួលជាមួយអនុប្រធានមណ្ឌលក្នុងការទំនាក់ទំនងជាមួយអ្នកប្រមូលទិញឲ្យបានជាប់ជាប្រចាំ<br>• សម្របសម្រួលការដឹកជញ្ជូនកសិផលពីកសិដ្ឋានរបស់សមាជិកនីមួយៗ មកកាន់មណ្ឌលប្រមូលផ្តុំកសិផលឲ្យមានសុវត្ថិភាព និងគ្រប់ចំនួនតាមការកំណត់<br>• ដាក់ផែនការប្រមូលកសិផលពីសមាជិកបណ្តុំនីមួយៗមកមណ្ឌល និងពីមណ្ឌលទៅទីផ្សារតាមការបញ្ជាទិញស្របតាមការឯកភាពគ្នា (បន្ថែមថ្លៃសេវាដឹកជញ្ជូន)។<br>• រៀបចំវិក័យប័ត្រ/បណ្ណទទួលកសិផលពីសមាជិកបណ្តុំអាជីវកម្មនីមួយៗ<br>• ផ្តល់ឯកសារពាក់ព័ន្ធដល់ហិរញ្ញឹកក្នុងការទូទាត់ថវិកាជូនសមាជិកបណ្តុំ<br>• មើលថែសម្ភារ និងមធ្យោបាយនានាសម្រាប់ការដឹកជញ្ជូនទៅអ្នកប្រមូលទិញ ឬ ទីផ្សារ ។ | • ត្រូវប្រាកដថា ព័ត៌មានអំពីការទិញ-លក់កសិផលជាមួយអ្នកប្រមូលទិញ និងមណ្ឌុំអាជីវកម្ម បានធ្វើបច្ចុប្បន្នភាពជាប្រចាំ និងទៀតទាត់<br>• ត្រូវប្រាកដថា កសិផលដែលត្រូវដឹកជញ្ជូនទៅទីផ្សារ ឬអ្នកប្រមូលទិញ មិនខូចគុណភាពពេលដឹក គ្រប់ចំនួនតាមការបញ្ជាទិញ និងទៀតទាត់<br>• ប្រមូលតាមផែនការដែលបានសម្រេចជាមួយសមាជិកដែលគ្រោងទុក<br>• មិនអោយបាត់បង់វិក័យបត្រទាំងអស់<br>• រក្សាសម្ភារវេចខ្ចប់មិនអោយបាត់បង់គុណភាព ឬបរិមាណសម្រាប់ផ្គត់ផ្គង់ជូនសមាជិកបណ្តុំ ដោយត្រូវទូទាត់ផ្ទាល់ដៃ ឬបណ្តាក់តាមការឯកភាពគ្នា។ |
| **ហិរញ្ញឹក/លេខា** | • កត់ត្រាចំណូល-ចំណាយពីសេវាចេញ-ចូលរបស់មណ្ឌលប្រមូលផ្តុំកសិផល<br>• គ្រប់គ្រងបញ្ជីចំណូល-ចំណាយរបស់មណ្ឌល<br>• ប្រគល់វិក័យបត្រ័ដែលជំពាក់អោយអ្នកដឹកជញ្ជូនទៅប្រមូលប្រាក់សម្រាប់ប្រគល់ជូនសមាជិកវិញ<br>• កត់ត្រាប្រតិបត្តិការផ្សេងៗ និងរៀបចំរបាយការណ៍ចំណូល-ចំណាយឲ្យបានច្បាស់លាស់ និងទៀងទាត់។ | • ត្រូវប្រាកដថា របាយការណ៍ទាន់ពេលវេលា<br>• ទុកដាក់បញ្ជីរស្មោមបានត្រឹមត្រូវ<br>• ដឹងច្បាស់អំពីប្រាក់ចេញ-ចូល និងទូទាត់<br>• ទទួលខុសត្រូវលើការបាត់ប្រាក់ ។ បើបាត់ប្រាក់គឺត្រូវសងមកវិញគ្រប់ចំនួន។ |

## ខ). គោលការណ៍ប្រើប្រាស់ និងថែទាំ

មណ្ឌលប្រមូលផ្ដុំកសិផលនេះ ត្រូវបានរៀបចំឡើងដើម្បីដាក់ជូនសមាជិកបណ្ដុំអាជីវកម្ម ដែលបង្កើតដោយកម្មវិធីASPIRE ប្រើប្រាស់។ កសិករក្រៅពីនេះ ក៏អាចប្រើប្រាស់មណ្ឌលនេះបានដែរ ប៉ុន្តែត្រូវប្ដេជ្ញាគោរពតាមលក្ខខណ្ឌ និងគោលការណ៍របស់មណ្ឌលជាមុនសិន។

កសិករក្រុមផលិត ត្រូវដឹកជញ្ជូនកសិផលរបស់ខ្លួនដែលបានវេចខ្ចប់រួចហើយមកដាក់នៅក្នុងមណ្ឌលនេះ ដើម្បីលក់ឲ្យអ្នកប្រមូលទិញតាមកិច្ចសន្យាដែលបានកំណត់។ ប្រធានមណ្ឌលជាអ្នកចាត់ចែង និងសម្របសម្រួលរួមលើកិច្ចការនេះ។

ដើម្បីគាំទ្រដល់កិច្ចដំណើរការ និងការថែទាំអគារមណ្ឌល រួមទាំងការបង់ថ្លៃសេវាទឹក អគ្គិសនី សេវាអ៊ីនធើណេត និងការចំណាយចាំបាច់មួយចំនួនទៀត កសិករក្រុមផលិតនៃបណ្ដុំអាជីវកម្ម ជាអ្នកទទួលរ៉ាប់រងទៅលើការចំណាយនេះ។ ជម្រើសនៃការប្រមូលថវិកាសម្រាប់ការចំណាយនេះ គឺមានពីររបៀប តាមការសម្រេចរបស់កសិករបណ្ដុំអាជីវកម្ម។ ជម្រើសទី១ គឺកសិករត្រូវចូលរួមបដិភាគជាសាច់ប្រាក់ រីឯជម្រើសទី២គឺ សមាជិកបណ្ដុំអាជីវកម្ម ត្រូវទិញភាគហ៊ុន។

- **ជម្រើសទី១៖ ការចូលរួមបដិភាគសាច់ប្រាក់** ៖ សមាជិកម្នាក់ៗត្រូវកាត់ថវិកាចំនួន៥%នៃថវិកាដែលលក់កសិផលបានក្នុងមួយលើកៗតាមរយៈការដឹកជញ្ជូនមកកាន់មណ្ឌលប្រមូលផ្ដុំកសិផលនេះ។

  **ឧទាហរណ៍៖** កសិករម្នាក់ ដឹកកសិផលរបស់គាត់មកលក់នៅមណ្ឌល ចំនួន១០គីឡូក្រាម។ មួយគីឡូក្រាមតម្លៃ ២ ០០០ រៀល។ ដូច្នេះតម្លៃលក់បានសរុបគឺ ២០ ០០០ រៀល។ គាត់ត្រូវកាត់ ៥% ឲ្យទៅគណៈកម្មការ គឺស្មើនឹង ១ ០០០ រៀល។ គណៈកម្មការត្រូវគ្រប់គ្រងចំណូលនេះ ដើម្បីទូទាត់ថ្លៃទឹក អគ្គិសនី សេវាអ៊ីនធើណេត និងប្រាក់ឧបត្ថម្ភគណៈកម្មការ (ប្រសិនបើមាន)។ ដំណាក់កាលដំបូងសមាជិកបណ្ដុំត្រូវបានកាត់៥% ប៉ុន្តែអត្រានេះក៏នឹងត្រូវបានកំណត់ឡើងវិញ នៅពេលដែលចំនួនថវិកានេះ មិនអាចរ៉ាប់រងការចំណាយបាន ឬចំណូលនេះច្រើនលើសលប់ពេក សម្រាប់រ៉ាប់រងការចំណាយជាក់ស្ដែង។

- **ជម្រើសទី២៖ ការទិញភាគហ៊ុន ៖** សមាជិកម្នាក់ៗត្រូវទិញភាគហ៊ុនពីមណ្ឌលប្រមូលផ្ដុំកសិផល។ ភាគហ៊ុននីមួយៗមានតំលៃស្មើៗគ្នា (ឧទាហរណ៍៖ ០១ភាគហ៊ុន មានតំលៃ ១០០ ០០០ រៀល) ក្នុងមួយហ៊ុន។ ទាំងសមាជិកគណៈកម្មការ និងសមាជិកបណ្ដុំអាជីវកម្មម្នាក់ៗ ត្រូវទិញ ០១ហ៊ុនយ៉ាងតិច ដើម្បីចូលរួមក្នុងកិច្ចប្រតិបត្តិការនិងការថែទាំមណ្ឌល និងទទួលបានប្រាក់ចំណេញទៅវិញ ។ ភាគហ៊ុននីមួយៗ អាចបង់តែមួយដង ឬសន្សំតាមខែក៏បាន អាស្រ័យលើការ

ឯកភាពគ្នា។ បន្ទាប់ពីភាគហ៊ុនត្រូវបានលក់អស់ គណៈកម្មការត្រូវគ្រប់គ្រងថវិកានេះ សំរាប់ទិញកសិផលពីសមាជិកបណ្តុំអាជីវកម្ម ដើម្បីលក់បន្តឲ្យអ្នកប្រមូលទិញតាមកិច្ចសន្យា (គណៈកម្មការគ្រប់គ្រងមណ្ឌលត្រូវស្វែងរកទីផ្សារកសិផល និងធ្វើកិច្ចសន្យាត្រឹមត្រូវជាមួយអ្នកប្រមូលទិញ)។ ថវិកាដែលចំណេញពីការលក់កសិផលនេះ គណៈកម្មការត្រូវរក្សាទុកមួយចំណែកសម្រាប់រ៉ាប់រងថ្លៃទឹក អគ្គិសនី និងសេវាអ៊ីនធើណេត និងមួយចំណែកទៀតសម្រាប់ឧបត្ថម្ភគណៈកម្មការ(បើមាន) ។ ថវិកាដែលនៅសល់ពីការចំណាយទាំងនេះ ត្រូវបែងចែកឲ្យសមាជិកបណ្តុំអាជីវកម្មដែលទិញភាគហ៊ុនវិញ។

**ឧទាហរណ៍៖** ភាគហ៊ុនដែលលក់បានសរុបមានចំនួន ៣ ០០០ ០០០រៀល។ មណ្ឌលប្រមូលផ្តុំកសិផល ទិញកសិកផលពីកសិករ០១គីឡូក្រាមតម្លៃ ១ ០០០រៀល ស្មើនឹង ៣ ០០០ គីឡូក្រាម។ មណ្ឌលលក់ចេញវិញបាន ០១គីឡូក្រាម ១ ៥០០រៀល ដូច្នេះ ៣ ០០០គក្រ x ១ ៥០០រៀល = ៤ ៥០០ ០០០ រៀល (ចំណេញបាន ១ ៥០០ ០០០រៀល)។ ប្រាក់ចំណេញនេះ ត្រូវឧបត្ថម្ភគណៈកម្មការ ២៥០ ០០០រៀល(បើមានគោលការណ៍នេះ), ថ្លៃទឹក អគ្គិសនី នឹងសេវាអ៊ីនធើណេត ២៥០ ០០០ រៀល នៅសល់ ១ ០០០ ០០០ រៀល ត្រូវបែងចែកឲ្យសមាជិកបណ្តុំចំនួន ៣០នាក់ គឺម្នាក់ៗទទួលបាន ៣៣ ០០០ រៀល។ ការបែងចែកភាគលាភនេះ នឹងត្រូវធ្វើឡើងជារៀងរាល់ខែ។ **ឬមួយយើងអាចគិតតាមរូបមន្តដូចខាងក្រោម៖**

- បែងចែកសម្រាប់ការឧបត្ថម្ភដល់គណៈកម្មការ ៥រូប ១៥% (បើមាន)
- បែងចែកដល់ម្ចាស់ភាគហ៊ុន ៧០%
- បែងចែកសម្រាប់រាប់រងការចំណាយលើថ្លៃ ទឹក អគ្គិសនី អ៊ីនធើណេត... ៥%
- រក្សាជាមូលនិធិបម្រុងទុកក្នុងមណ្ឌល ១០% សម្រាប់ពង្រីកមុខរបរបន្ថែម

- **ជម្រើសផ្សេងៗទៀត៖** គណៈកម្មការគ្រប់គ្រងមណ្ឌលប្រមូលផ្តុំកសិផល អាចប្រជុំជាមួយសមាជិក បណ្តុំអាជីវកម្មរបស់ខ្លួន ដើម្បីពិភាក្សារកជំរើសនៃការរ៉ាប់រងការចំណាយលើថ្លៃទឹក អគ្គិសនី អ៊ីនធើណេត ដែលសមស្របនឹងស្ថានភាពរបស់ខ្លួនបាន ។ ជម្រើសថ្មីនេះ ត្រូវមានការឯកភាពពីគណៈកម្មការគ្រប់គ្រងមណ្ឌល និងសមាជិកបណ្តុំអាជីវកម្មយ៉ាងហោចណាស់ ២/៣នៃសមាជិកទាំងមូល។

## ៥. គោលការណ៍នៃការធ្វើអាជីវកម្ម

នៅពេលអគារមណ្ឌលប្រមូលផ្តុំកសិផលត្រូវបានសាងសង់រួចរាល់ ដោយមានការជួយគាំទ្រពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត បណ្តុំអាជីវកម្មដែលប្រើប្រាស់មណ្ឌលនេះ មានកាតព្វកិច្ចជាចាំបាច់ ត្រូវរៀបចំឲ្យមាន៖ (១).ប្រជុំផ្សព្វផ្សាយអំពីការគ្រប់គ្រងនិងប្រើប្រាស់

មណ្ឌលប្រមូលផ្តុំកសិផលដល់សមាជិកបណ្តុំអាជីវកម្មរបស់ខ្លួនទាំងអស់ និងអាជ្ញាធរមូលដ្ឋានពាក់ព័ន្ធ (២).រៀបចំឲ្យមានគណៈកម្មការគ្រប់គ្រងមណ្ឌល (៣).រៀបចំបទបញ្ជាផ្ទៃក្នុងអំពីការគ្រប់គ្រង ការប្រើប្រាស់ និងថែទាំមណ្ឌល (៤).ចាត់ចែងប្រមូលទុនសហវិនិយោគដើម្បីទិញសម្ភារបំពាក់ក្នុងអគារមណ្ឌល ដូចជា ទូ/ធ្នើដាក់កសិផល តប្រព័ន្ធទឹកនិងអគ្គិសនីជាដើម (៥).រៀបចំផែនការដាំដុះ ចិញ្ចឹម ដើម្បីផ្គត់ផ្គង់ឲ្យអ្នកប្រមូលទិញស្របតាមកិច្ចសន្យា (៦).បណ្តុះបណ្តាលអំពីបច្ចេកទេសនានា(បើចាំបាច់) (៧).ដំណើរការទិញ-លក់កសិផល ធាតុចូលកសិកម្ម និងសម្ភារនានាតាមកិច្ចសន្យាអាជីវកម្មតាមរយៈមណ្ឌលនេះ ...។

ដំណើរការអាជីវកម្មអាចនឹងប្រែប្រួលអាស្រ័យដោយប្រភេទផលិតផល (ផលិតផលខ្លះអាចឆាប់រលួយ ឬបាត់បង់គុណភាព ផលិតផលខ្លះអាចទុកបានយូរមួយរយៈពេលកំណត់) ស្ថានភាពជាក់ស្តែងនៃផលិតកម្ម និងលក្ខខណ្ឌភូមិសាស្ត្រជាដើម ។ ទោះជាយ៉ាងនេះក្តី ដើម្បីឲ្យបណ្តុំអាជីវកម្មមាននិរន្តរភាពនោះ បណ្តុំអាជីវកម្មនីមួយៗត្រូវប្រកាន់យកនូវគោលការណ៍ចាំបាច់មួយចំនួនដូចខាងក្រោម៖

៥.១. មានភាពស្មោះត្រង់រវាងគ្រប់តួអង្គនៃបណ្តុំ (ក្រុមអ្នកផលិត អ្នកផ្គត់ផ្គង់ធាតុចូល និងអ្នកប្រមូលទិញ ។ល។) ដើម្បីកសាងបាននូវទំនុកចិត្ត ដែលជាគន្លឹះនៃការយោគយល់គ្នា ចែក ផលចំណេញគ្នា ទោះបីតិចតួចក៏ដោយ (ចំណេញបន្តិចម្នាក់ៗរវាងគ្រប់តួអង្គ) ស្របទៅនឹងពាក្យស្លោកថា « រត់លឿនម្នាក់ឯង រត់បានទីខ្លី តែបើរត់ជាក្រុមជាមួយគ្នា ទើបរត់បានឆ្ងាយ »

៥.២. រួមគ្នាកសាង ឬ កែលម្អ និងថែរក្សាមណ្ឌលប្រមូលផ្តុំកសិផល និងរួមគ្នាដោះស្រាយក្នុងករណីមានបញ្ហាមួយកើតឡើងជាយថាហេតុ ហើយដែលតួអង្គណាមួយ មិនអាចដោះស្រាយបានដូចជា៖

- ការធ្លាក់ចុះថ្លៃផលិផលភ្លាមៗនៅលើទីផ្សារទូទៅ
- ករណីប្រធានស័ក្តិ៖ គ្រោះធម្មជាតិដែលបណ្តាលឲ្យខូចខាតមណ្ឌល ឬវិបត្តិសង្គមជាដើម។

៥.៣. មានសាមគ្គីភាពផ្ទៃក្នុង រវាងសមាជិកក្នុងក្រុមកសិករផលិត៖

- រួមគ្នាធ្វើផែនការផលិតកម្ម ដោយត្រូវផ្លាស់ប្តូរវេន និងពេលវេលាផលិតកសិផល (ក្រោយពីដឹងអំពីតម្រូវការទីផ្សារ) ដោយធ្វើយ៉ាងណាឲ្យមានផលិតផលគ្រប់មុខផ្គត់ផ្គង់អ្នកទិញ ឬទីផ្សារបានជាប្រចាំ តែជៀសវាងការជួយផលិតផលដែលធ្វើឲ្យមានការខាតបង់

- ផ្តល់យោបល់កែលម្អគ្នាទាំងស្មារតី និងទាំងបច្ចេកទេស ដោយត្រូវអនុវត្តតាមបច្ចេកទេសដែលកម្មវិធី ASPIRE ផ្តល់ជូន ឬ កំណត់ដោយក្រុមហ៊ុនប្រមូលទិញ
- លើកទឹកចិត្តគ្នា យល់អធ្យាស្រ័យគ្នា ជួយគ្នានូវមធ្យោបាយ សម្ភារ ប្រកបដោយសមធម៌
- មានទិសដៅរួមគ្នា គឺការលើកកម្ពស់គុណភាពផលិតផល ជៀសវាងការបន្ថំគុណភាព ដែលធ្វើឲ្យបាត់បង់ជំនឿទុកចិត្តពីអ្នកទិញកសិផលពីបណ្តុំ (ត្រីមួយកន្ត្រកស្អុយមួយ ស្អុយទាំងអស់)
- រួមគ្នាគោរពវិន័យផ្ទៃក្នុងក្រុមផលិត រាប់តាំងពីពេលវេលាដែលបានណាត់ជួបប្រជុំពិភាក្សា ការមកទទួលធាតុចូល (ក្នុងករណីទិញមកជាដុំ និងបែងចែកគ្នា) ការប្រមូលផល និងដឹកជញ្ជូនមកដល់មណ្ឌល ... ជាដើម។

## ៦. តួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធ

### ៦.១ លេខាធិការដ្ឋានកម្មវិធីASPIRE

លេខាធិការដ្ឋានកម្មវិធីASPIRE មានតួនាទី និងការទទួលខុសត្រូវដូចខាងក្រោម៖

- សម្របសម្រួលរៀបចំគំនូសប្លង់អគារមណ្ឌលប្រមូលផ្តុំកសិផល
- សម្របសម្រួលក្នុងការជ្រើសទីតាំងសាងសង់
- សម្របសម្រួលពិនិត្យដំណើរការសាងសង់
- រៀបចំសេចក្តីណែនាំស្តីពីការគ្រប់គ្រង និងប្រើប្រាស់មណ្ឌលប្រមូលផ្តុំកសិផល
- សម្របសម្រួល និងគាំទ្រអ្នកពាក់ព័ន្ធដើម្បីជំរុញដល់កិច្ចដំណើរការមណ្ឌលប្រមូលផ្តុំ។

### ៦.២ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

- សម្របសម្រួល និងជ្រើសរើសទីតាំងសាងសង់អគារមណ្ឌលប្រមូលផ្តុំកសិផលដែលសមស្របដើម្បីជួយសម្រួលដល់បណ្តុំអាជីវកម្ម ក្នុងការដឹកជញ្ជូនកសិផលមកអគារមណ្ឌលប្រមូលផ្តុំនេះ
- រៀបចំកិច្ចសន្យាផ្តល់ដីសម្រាប់សាងសង់អគារមណ្ឌលប្រមូលផ្តុំកសិផល ជាមួយកសិករដែលយល់ព្រមដោយស្ម័គ្រចិត្តផ្តល់ដីសម្រាប់សាងសង់អគារដើម្បីប្រើប្រាស់ជាប្រយោជន៍រួមនេះ
- សម្របសម្រួល និងតាមដានត្រួតពិនិត្យដំណើរការ និងលទ្ធផលនៃការសាងសង់អគារមណ្ឌល

- ផ្សព្វផ្សាយ/បណ្តុះបណ្តាលដល់បណ្តុំអាជីវកម្ម អំពីផលប្រយោជន៍ ការគ្រប់គ្រង ការប្រើប្រាស់ និងការថែទាំមណ្ឌលប្រមូលផ្តុំកសិផល
- សម្របសម្រួល និងជួយគាំទ្របណ្តុំអាជីវកម្មលើកិច្ចដំណើរការរបស់មណ្ឌលប្រមូលផ្តុំកសិផលទាំងមូល
- គាំទ្រកិច្ចការផ្សេងៗទៀត តាមការស្នើសុំរបស់បណ្តុំអាជីវកម្ម និងអាជ្ញាធរមូលដ្ឋានសម្រាប់ជំរុញដល់ប្រតិបត្តិការរបស់មណ្ឌលប្រមូលផ្តុំកសិផលនេះ ឲ្យដំណើរការដោយរលូន និងមាននិរន្តរភាព។

## ៦.៣ គណៈកម្មការគ្រប់គ្រងមណ្ឌលប្រមូលផ្តុំកសិផល

- សម្របសម្រួលរៀបចំផែនការទិញ-លក់កសិផលតាមការបញ្ជាទិញរបស់អ្នកប្រមូលទិញ
- សម្របសម្រួលការងារពិនិត្យគុណភាព និងបរិមាណកសិផល ការដឹកជញ្ជូន និងការវេចខ្ចប់កសិផល តាមកិច្ចសន្យាដែលបានព្រមព្រៀងជាមួយអ្នកប្រមូលទិញ
- រៀបចំប្រជុំសមាជិកបណ្តុំអាជីវកម្ម ដើម្បីពិភាក្សាអំពីផែនការដាំដុះ ចិញ្ចឹម ស្របតាមកិច្ចសន្យាបញ្ជាទិញ ផ្តល់ព័ត៌មានទីផ្សារ ការផ្គត់ផ្គង់ធាតុចូល ដោះស្រាយបញ្ហា និងការពិភាក្សាអំពីថវិកាដែលត្រូវចំណាយលើទឹក អគ្គិសនី សេវាអ៊ីនធើណេត ...ជាដើម
- រៀបចំកិច្ចប្រជុំប្រចាំខែឲ្យបានទៀតទាត់ ដើម្បីគ្រប់គ្រងកិច្ចដំណើរការអាជីវកម្មក្នុងមណ្ឌលប្រមូលផ្តុំកសិផលនេះ និងការអនុវត្តតួនាទីភារកិច្ចរបស់គណៈកម្មការឲ្យមានប្រសិទ្ធភាព។

## ៦.៤ បណ្តុំអាជីវកម្ម-កសិករអ្នកផលិត

- ធ្វើការដាំដុះ ឬចិញ្ចឹមតាមផែនការដែលបានកំណត់ក្នុងកិច្ចសន្យាទិញ-លក់កសិផល
- ដឹកជញ្ជូនកសិផលមកដាក់ក្នុងអគារប្រមូលផ្តុំកសិផល តាមការបញ្ជាទិញរបស់អ្នកប្រមូលទិញ
- អនុវត្តតាមលក្ខខ័ណ្ឌដែលបានឯកភាពក្នុងការទិញ-លក់កសិផល
- ចូលរួមទុនសហវិនិយោគ សម្រាប់ចំណាយលើ សម្ភារ ឧបករណ៍ សម្រាប់ដាក់កសិផលក្នុងអគារមណ្ឌល និងបដិភាគជាថវិកាសម្រាប់គាំទ្រការចំណាយលើសេវាទឹក អគ្គិសនី សេវាអ៊ីនធើណេត និងចំណាយផ្សេងៗទៀតតាមការចាំបាច់
- ចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងព្រឹត្តិការណ៍នានា តាមការកោះប្រជុំរបស់ប្រធានគណៈកម្មការគ្រប់គ្រងមណ្ឌល និងតាមការចាំបាច់របស់អ្នកពាក់ព័ន្ធ។

## ៦.៥ កសិករម្ចាស់ទីតាំងអគារមណ្ឌល

- ចូលរួមផ្តល់ដីដោយស្មគ្រ័ចិត្ត សម្រាប់សាងសង់អគារមណ្ឌលប្រមូលផ្តុំកសិផល ដើម្បីប្រើប្រាស់ជាប្រយោជន៍រួមរបស់បណ្តុំអាជីវកម្ម
- ចូលរួមថែរក្សាអគារមណ្ឌល និងសម្ភារ ឧបករណ៍នានាដែលមានក្នុងបរិវេណមណ្ឌល
- ប្រើប្រាស់អគារមណ្ឌលជាប្រយោជន៍រួម និងតាមការសម្រេចរបស់គណៈកម្មការគ្រប់គ្រងមណ្ឌលប្រមូលផ្តុំកសិផល។

## ៦.៦ អាជ្ញាធរមូលដ្ឋាន

អាជ្ញាធរមូលដ្ឋានសំដៅដល់ អាជ្ញាធរភូមិ ឃុំ/សង្កាត់ មានតួនាទីដូចខាងក្រោម៖

- សម្របសម្រួល និងដោះស្រាយវិវាទនានាដែលកើតមានឡើង ដោយការប្រើប្រាស់មណ្ឌលប្រមូលផ្តុំកសិផលនេះ
- ដោះស្រាយបញ្ហានានា តាមសំណូមពររបស់គណៈកម្មការគ្រប់គ្រងមណ្ឌល និងបណ្តុំអាជីវកម្ម
- ជំរុញ លើកទឹកចិត្តដល់បណ្តុំអាជីវកម្ម ក្នុងការប្រើប្រាស់មណ្ឌលនេះប្រកបដោយនិរន្តរភាព
- សហការ និងសម្របសម្រួលជាមួយរដ្ឋបាលស្រុក/ក្រុង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត ក្នុងការគាំទ្រ ឬ/និងដោះស្រាយបញ្ហានានាពាក់ព័ន្ធនឹងការប្រើប្រាស់មណ្ឌល និងទំនាស់ផលប្រយោជន៍ផ្សេងៗ។




## ៧. ទម្រង់ឯកសារនានា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ខេត្ត ៖ ............

ស្រុក ៖ ............

ឃុំ ៖ ............

**កិច្ចសន្យាផ្តល់ដី**

**សម្រាប់សាងសង់អគារមណ្ឌលប្រមូលផ្តុំកសិផល ដើម្បីប្រើប្រាស់ជាប្រយោជន៍រួម**

ខ្ញុំបាទឈ្មោះ ................................ ជាប្តី និងនាងខ្ញុំឈ្មោះ................................... ត្រូវជាប្រពន្ធ នៅភូមិ...................... ឃុំ ...................... ស្រុក.................. ខេត្ត.......................។

បានព្រមព្រៀងឯកភាពគ្នា និងស្ម័គ្រចិត្តផ្តល់ដីទំហំ ............ម៉ែត្រការេ ដែលមានទីតាំងស្ថិតនៅភូមិ................ ឃុំ................. ស្រុក.................. ខេត្ត.............. ឲ្យទៅបណ្តុំអាជីវកម្ម.................. ដើម្បីសាងសង់អគារមណ្ឌលប្រមូលផ្តុំកសិផល សម្រាប់ប្រើប្រាស់ជាប្រយោជន៍រួមរបស់សមាជិកទាំងអស់ រយៈពេល០៥ឆ្នាំ គិតចាប់ពីឆ្នាំ........ ដល់ឆ្នាំ..........។ បន្ទាប់ពីឆ្នាំ........តទៅ បណ្តុំអាជីវកម្មដែលប្រើប្រាស់មណ្ឌលនេះ ត្រូវបង់ថ្លៃជួលដីទំហំ.....ម៉ែត្រការេនេះ មកខ្ញុំបាទ/នាងខ្ញុំ តាមការកំណត់របស់គណៈកម្មការគ្រប់គ្រងមណ្ឌល ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ និងមានការឯកភាពពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត...........។ ខ្ញុំបាទ/នាងខ្ញុំ យល់ព្រមទទួលយកតម្លៃជួលដី តាមការកំណត់របស់គណៈកម្មការគ្រប់គ្រង់មណ្ឌល។

ដើម្បីជាភស្តុតាងនៃការស្ម័គ្រចិត្តផ្តល់ដីទំហំ.......... ម៉ែត្រការេនេះ យើងខ្ញុំសូមផ្តិតមេដៃទុកជាចំណាំ។

ធ្វើនៅ.................... ថ្ងៃ.......................... ខែ............ ឆ្នាំ.......... ព.ស ២៥៦៤

.............. ថ្ងៃទី......... ខែ............ ឆ្នាំ.............។

ស្នាមមេដៃ(ប្តី) ស្នាមមេដៃ(ប្រពន្ធ)

សាក្សី

......................... ...............................

.......................................

មេភូមិ................

បានឃើញ និងបញ្ជាក់ថា

.............................................

*បានឃើញ និងឯកភាព*

....................................................

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្ត

មេឃុំ....................

**បណ្ណទិញ-លក់ ភាគហ៊ុន** (**ករណីយកជម្រើសនេះ**)

គណៈកម្មការគ្រប់គ្រងអគាប្រមូលផ្ដុំកសិផលភូមិ..................... ឃុំ................... ស្រុក ........................ ខេត្ត............................។

បានលក់ភាគហ៊ុនចំនួន.............ភាគហ៊ុន (១០០.០០០រៀល/ភាគហ៊ុន) ឲ្យទៅឈ្មោះ ............................ភេទ.......... រស់នៅក្នុងភូមិ............... ឃុំ..................ស្រុក................ ខេត្ត...................... ដែលមានទឹកប្រាក់សរុប.......................................រៀល

ថ្ងៃទី ........... ខែ.............. ឆ្នាំ.................

អ្នកលក់ភាគហ៊ុន អ្នកទិញភាគហ៊ុន

................................ ................................

ឈ្មោះ ................................ ឈ្មោះ ................................

## សៀវភៅកត់ត្រាចំណូល-ចំណាយប្រចាំខែ..(មករា)....២០២១..

## របស់អគារប្រមូលផ្ដុំកសិផល

| កាលបរិច្ឆេទ | បរិយាយ | ចំណូល (រៀល) | ចំណាយ (រៀល) | សរុបសាច់ប្រាក់ (សមតុល្យ) (រៀល) |
|---|---|---|---|---|
| 01-មករា-2021 | ថវិកាលក់ភាគហ៊ុន (៣០ភាគហ៊ុន) | 3,000,000 | | 3,000,000 |
| 02-មករា-2021 | ទិញកសិផល | | 3,000,000 | - |
| 10-មករា-2021 | លក់កសិផល | 4,500,000 | | 4,500,000 |
| 30-មករា-2021 | ប្រាក់ឧបត្ថមគណៈកម្មាការ | - | 250,000 | 4,250,000 |
| 30-មករា-2021 | ថ្លៃទឹក ភ្លើង សេវាអ៊ីនធើណេត | | 250,000 | 4,000,000 |
| 30-មករា-2021 | បែងចែកប្រាក់ចំណេញដល់៣០ភាគហ៊ុន | | 900,000 | 3,100,000 |
| សរុបចំណូល-ចំណាយប្រចាំខែ | | 7,500,000 | 4,400,000 | 3,100,000 |

# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងរបស់មណ្ឌលប្រមូលផលផ្តុំកសិផល

**ប្រការ ១** ៖ មណ្ឌលប្រមូលផលផ្តុំកសិផលនេះ ត្រូវបានគ្រប់គ្រងដោយគណៈកម្មាការមួយ ដែលកើតឡើងពីការបោះឆ្នោតដោយសមាជិកបណ្តុំអាជីវកម្ម មានអាណត្តិ ០៣ ឆ្នាំ។ សមាជិកបណ្តុំអាជីវកម្មមានសិទ្ធិឈរឈ្មោះជាបេក្ខជនសម្រាប់បោះឆ្នោតជ្រើសរើសគណៈកម្មាការនេះ។

**ប្រការ ២** ៖ គណៈកម្មាការគ្រប់គ្រងមណ្ឌលប្រមូលផលផ្តុំកសិផល មិនទទួលបានប្រាក់បៀវត្សន៍ប្រចាំខែទេ។

**ប្រការ ៣** ៖ សមាជិកបណ្តុំអាជីវកម្មទាំងអស់ ត្រូវគោរពតាមលក្ខខណ្ឌ និងតម្រូវការរបស់អ្នកទិញ

**ប្រការ ៤** ៖ សមាជិកបណ្តុំអាជីវកម្មទាំងអស់ ត្រូវដាំដុះ និងចិញ្ចឹម តាមគោលការណ៍នៃការអនុវត្តកសិកម្មល្អ(GAP និង GAHP) ។ កសិផលដែលដាក់លក់ក្នុងមណ្ឌលនេះ ជាកសិផលសុវត្ថិភាព។

**ប្រការ ៥** ៖ សមាជិកបណ្តុំអាជីវកម្មទាំងអស់ ត្រូវបែងចែកគុណភាពនិងវេចខ្ចប់កសិផលរបស់ខ្លួនតាមគុណភាពនីមួយៗឲ្យបានស្អាត មាននាម័យ និងដឹកជញ្ជូន មកដាក់ក្នុងមណ្ឌលនេះនៅវេលាម៉ោង .......................... រៀងរាល់ថ្ងៃ ឲ្យបានទៀតទាត់។

**ប្រការ ៦** ៖ សមាជិកបណ្តុំអាជីវកម្មទាំងអស់ ត្រូវចូលរួមវិភាគទានថវិកា ដើម្បីគាំទ្រការចំណាយលើថ្លៃអគ្គិសនី ទឹក សេវាអ៊ីនធើណេតប្រចាំខែ និងទុនសហវិនិយោគសម្រាប់ទិញសម្ភារ ឧបករណ៍ និងជួសជុលថែទាំអគារមណ្ឌលជាដើម ។ គណៈកម្មាការគ្រប់គ្រងមណ្ឌលត្រូវសម្របសម្រួលកិច្ចការនេះ ។

**ប្រការ ៧** ៖ កសិករក្រៅបណ្តុំអាជីវកម្ម អាចយកកសិផលរបស់ខ្លួនមកលក់ក្នុងមណ្ឌលនេះបាន ប៉ុន្តែត្រូវគោរពតាមលក្ខខណ្ឌក្នុងប្រការ៣ ប្រការ៤ ប្រការ៥ ប្រការ៦ និងដោយមានការឯកភាពពីគណៈកម្មាការគ្រប់គ្រងមណ្ឌល ដោយសម្លេង ២/៣ (៤នាក់/៥នាក់យ៉ាងតិច)។